**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ២០៧
ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៩
សាលដីកា
លេខៈ ១៤៥
ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០០០

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ............ ជាចៅក្រមរបាយការណ៍
៣-លោក ............ ជាចៅក្រម
៤-លោក ............... ជាចៅក្រម
៥-លោក ............ ជាចៅក្រម

ក្រឡាបញ្ជី

-កញ្ញា ...............

តំណាងមហាអយ្យការ

-លោក ............ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខសាលដីកា២១៦ ចុះថ្ងៃទី០៦ខែឧសភា ឆ្នាំ ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៨៥ ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ឈចថ ភេទ ស្រី អាយុ ៣៣ ឆ្នាំ ជាតិ ខ្មែរ មុខរបរ មេផ្ទះ មានទីលំនៅ ផ្ទះលេខ ២២B ផ្លូវលេខ ៦៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន ក្រុងភ្នំពេញ។

មានមេធាវី លោក ............

និង ចុងបណ្តឹងសាទុក្ខឈ្មោះ ជម ភេទ ស្រី អាយុ ៣៨ ឆ្នាំ ជាតិខ្មែរ តំណាងឲ្យធនាគារសឹង្ហបូរីទីលំនៅ ផ្ទះលេខ ៦៨ ផ្លូវសម្តេចប៉ាន សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

**កម្មវត្ថុបណ្តឹងៈ** ប្តឹងទាមទារប្រាក់ ១០.០០០.០០ ដុល្លារ

បានឃើញបណ្តឹងសាទុក្ខលេខ ១៩៥ ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ១៩៩៩ របស់លោក ............ ជាមេធាវី របស់អ្នកស្រី ឈចថ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ២១៦ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២០៧ ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៩៧ របស់ឈ្មោះ ឈចថ ប្តឹងទាមទារប្រាក់ចំនួន ១០.០០០.០០ ដុល្លាអាមេរិក ពីសាជីវកម្មសឹង្ហបូរី ដោយសំអាងថាប្តីខ្លួនឈ្មោះដឹម ច័ន្ទសាស្ត្រា ម្ចាស់គណនីលេខ ២១០០៥០១ នៅសាជីវកម្មសឹង្ហបូរី ក្រោយពីទទួលមរណភាពនា

ពេលបំពេញបេសកម្មអង្គការសហប្រជាជាតិ ឯប្រទេស រ៉្វាន់ដា កាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ មកធនាគារនេះបានឃុបឃិតដោយរំលោភបំពានបច្ចេកទេសធនាគារក្នុងការផ្ទេរប្រាក់ចេញពីគណនីរបស់ប្ដីខ្លួនមកគណនីរបស់ ឪពុកក្មេកខ្លួនដោយអនុញ្ញាតឲ្យឪពុកក្មេកខ្លួនបើកប្រាក់នោះទាស់តែអស់ ទោះបីខ្លួនធ្វើការតវ៉ាយ៉ាងណាក៏ដោយ ។ ដូចនេះខ្លួនសុំទាមទារប្រាក់ចំនួន ១០.០០០.០០ ដុល្លា នេះទុកចិញ្ចឹមកូន ៣នាក់ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១២(ង) ចុះថ្ងៃទី ២៩ខែឧសភា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ សម្រេចក្ដីចំពោះមុខគូក្ដីដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៩៧ និងចុះថ្ងៃទី ១៣ ខែមករា ឆ្នាំ១៩៩៨ របស់ដើមចោទឈ្មោះ ឈចថ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទទួលស្គាល់ឈ្មោះ ឈចថ កូនឈ្មោះ ជឹម សាំងវិ សូនាថ,ជឹម សាំងសូមនា និង ជឹម សាំងសមនា ជាសន្តិតិជន នៃសពឈ្មោះ ជឹម ច័ន្ទសាស្ត្រា ដែលមរណភាពកាលពីថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ ១៩៩៧ ចាប់ពីពេលសេចសម្រេច នេះចូលជាស្ថាពរតទៅ ។

៣-បង្គាប់ឲ្យធនាគារសាជីវកម្មសឹង្ហបូរី ចំកាត់សង់ប្រាក់ចំនួន ៨៨៩៣,១៦ ដុល្លាអាមេរិក ឲ្យទៅឈ្មោះ ឈចថ,ជឹម សាំងវិសូនាថ,ជឹម សាំងសូមនា,ជឹម សាំងសមនោ ព្រមទាំងប្រាក់ចំនួន ៥ ភាគរយក្នុងមួយឆ្នាំ ចាប់គិតពីថ្ងៃដាក់ពាក្យបណ្ដឹងចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ១៩៩៧ រហូតដល់ថ្ងៃសង និងជម្ងឺចិត្តចំនួន ១០០០០០៛ (មួយលានរៀល) សំណូមពរលើសពី នេះត្រូវបដិសេធចោល ចាប់គិតពីពេលសេចក្ដីសម្រេចចូលជាស្ថាពរតទៅ ។

៤-បង្គាប់ឲ្យធនាគារសាជីវកម្មសឹង្ហបូរី ចំកាត់បង់ប្រាក់ប្រដាប់ក្ដីចំនួន ៧០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ចំនួន ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ចំនួន ៥០០០៛ បូករួម ៧០០០៛ ប្រាក់នេះត្រូវកាត់យកពីប្រាក់ ៧០០០៛ ដែលដើមចោទបានបង់រួចហើយ ។ កាលបើហួសកំណត់ប្ដឹងឧទ្ធរណ៍ បង្គាប់ឲ្យធនាការសាជីវកម្មសឹង្ហបូរី សងប្រាក់ ៧០០០៛ ឲ្យដើមចោទវិញ និងបង់ពន្ធសមាមាត្រមួយភាគរយលើប្រាក់ជំពាក់ ជម្ងឺចិត្ត និងការប្រាក់ ប្រាក់នេះបង់ចូលថវិការដ្ឋចំនួន ៨០ ភារយរង្វាន់ក្រឡាបញ្ជី ទូទាំងប្រទេសចំនួន ២០ ភាគរយ ។

៥-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូភាគីសម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ១៩៩៨ របស់ឈ្មោះ ជម តំណាងឲ្យធនាគារសឹង្ហបូរីប្ដឹងមិនសុខចិត្ត និងសាលក្រមរដ្ឋប្បវេណីលេខ ១២(ង) ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ ២១៦ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ សម្រេចសេចក្ដីចំពោះមុខឈ្មោះ ជម, ជឹម សាំង មេធាវី ឈ្មោះ ជូ ចាន់ធារ៉ា ,មេធាវីឈ្មោះ ............ កំបាំងមុខឈ្មោះ ឈចថ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១-ទទួពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ១៩៩៨ របស់ឈ្មោះ ជម តំណាងធនាគារសឹង្ហបូរី ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ១២(ង) ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ចោលជាអាសារបង់ ។

៣-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៩ ខែឧសភា ឆ្នាំ១៩៩៧ របស់ឈ្មោះ ឈចថ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

៤-ទុកសិទ្ធិជូនឈ្មោះ ឈចថ ក្នុងការប្តឹងទាមទារប្រាក់ពីឈ្មោះ ជឹម សាំង ។

៥-សម្រេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤៥០៛ ចំណាយលើកការប្រគល់ដីកាកោះ ៥០០០៛ និងលើអាជ្ញាធរតុលាការ ៥០០០៛ ។

-កាលបើសាលដីកានេះចូលជាស្ថាពរហើយបង្គាប់ឲ្យឈ្មោះ ឈចថ សងប្រាក់ ១៣០០០៛ នេះទៅតំណាងធនាគារសឹង្ហបូរី វិញ និងបង្គាប់ឲ្យឈ្មោះ ឈចថ បង់ពន្ធសមាមាត្រមួយភាគរយ លើទឹកប្រាក់ចំនួន ៨៨៩៣,១៦ ដុល្លា ។ ប្រាក់នេះដាក់ចូលថវិការដ្ឋ ៨០ ភាគរយ និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយ ។

៦-សាលដីកានេះជំនុំជំរះនៅថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៩៩ ចំពោះមុខឈ្មោះ ជម ជិន សាង មេធាវីឈ្មោះ ជូ ចាន់ធារ៉ា,មេធាវីឈ្មោះ ........... កំបាំងមុខឈ្មោះ ឈចថ ប្រកាស ជាសាធារណៈថ្ងៃទី ០៧ ខែឧសភា ឆ្នាំ១៩៩៩ ចំពោះមុខ ជូ ចាន់ធារ៉ា និងឈ្មោះ ជម ។

-សម្រេចបើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៩៥ ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ១៩៩៩ របស់លោក ........... ជាមេធាវី របស់អ្នកស្រី ឈចថ ប្តឹងមិនសុខចិត្តនិងសាលដីកាលេខ ២១៦ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាការពារចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ១៩៩៩ របស់អ្នកស្រី ឈចថ

បានឃើញសារណាតបចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០០០ របស់ឈ្មោះ ជម ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈសាលដីការដ្ឋប្បវេណីលេខ ២១៦ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់អ្នកស្រី ឈចថ ជាដើមចោទ និងជាដើមបណ្តឹងសាទុក្ខបានឆ្លើយនៅពេលជំនុំជំរះថាៈ សាលាឧទ្ធរណ៍កាត់នេះមិនត្រឹមត្រូវព្រោះលុយនេះជាលុយប្តីរបស់ខ្លួន ខ្លួនសុំលុយនេះយកទៅចិញ្ចឹមកូនខ្លួននៅភ្នំពេញឪពុកក្មេក និងប្អូនខ្លួននៅកោះដាច់ ហើយលុយដែលប្តីខ្លួន

ផ្ញើមកតាមរយៈប្អូន និងឪពុកក្មេកនេះឯង ។ ធនាគារមិនបានដឹងថាប្តីខ្លួនបានស្លាប់ទេ គឺដឹងនៅពេលឪពុកក្មេកខ្លួនយកលិខិតពីខាងសិទ្ធិមនុស្សទៅបង្ហាញ និងសុំបើកប្រាក់នេះ ។

ក្រឡាបញ្ជីអានសារណាតបរបស់អ្នកស្រី ជម ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី ........... ការពារឲ្យអ្នកស្រី ឈចថ នៅពេលជំនុំជំរះថា: លោក ជឹម ចន្ទ័សាស្ត្រា ពិតជាប្តីប្រពន្ធស្របច្បាប់ជាមួយអ្នកស្រី ឈចថ ប្រាកដមែន ដូចមានពាក្យសុំរៀបអាពាហ៍ពិពាហ៍ចុះថ្ងៃទី ២៥ ខែតុលា ឆ្នាំ១៩៨៦ ជាភស្តុតាងស្រាប់ និងនៅក្នុងប្រវត្តិរូបផ្ទាល់ខ្លួនធ្វើជាមួយអង្គការសហប្រជាជាតិនៅថ្ងៃទី ១៤ ខែតុលា ឆ្នាំ១៩៩៤ បញ្ជាក់ថាក្រោយពីបានរួមរស់ជាមួយគ្នាជាប្តីប្រពន្ធ២នាក់នេះមានកូន៣នាក់ ។

ក្រោយពីបានស្លាប់នៅក្នុងបេសកម្មការងារលោក ជឹម ចន្ទ័ សាស្ត្រា បានបន្សល់ទុកប្រាក់ចំនួន ៨.៨៩៣,១៦ ដុល្លា នៅក្នុងគណនីសាជីវកម្មធនាគារសឹង្ហបូរី ចំកាត់ ។ក្រោយពីបានទទួលដំណឹងមរណភាពរបស់លោក ជឹម ចន្ទ័សាស្ត្រា ធនាគារសម្រេចបើកប្រាក់ នេះឲ្យទៅលោក ជឹម សាំង និងប្អូន ជឹម ចន្ទ័ដារ៉ារិទ្ធ ទាំងអស់ ឯទាយាទកូនបង្កើតនៃសពមិនបានទទួលសូម្បីតែ ១ដុល្លា ។ ចំពោះទង្វើនេះតើត្រឹមត្រូវតាមគោលការណ៍ទូទៅនៃនីតិដែរ ឬទេ ? បើផ្អែកតាមទំនាមទំលាប់សង្គមខ្មែរបច្ចុប្បន្ន បើប្តីស្លាប់ប្រពន្ធជា អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ តែបើផ្អែកតាមគោលការណ៍នៃនីតិវិញ គឺកូនដែលជាទាយាទថ្នាក់ទី១ ជាអ្នកទទួលមរតកពីឪពុក ។

អាស្រ័យហេតុនេះសូមឯកឧត្តមប្រធានតុលាការកំពូល និងក្រុមប្រឹក្សាជំនុំជំរះមេត្តាសម្រេចបដិសេធសាលដីកាសាលាឧទ្ធរណ៍ចោជាអសាបង់ ហើយបង្វិលឲ្យសាលាឧទ្ធរណ៍ជំនុំជំរះឡើងវិញដោយអនុគ្រោះ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រី ជឹម ម៉ៅ តំណាងធនាគារសឹង្ហបូរី ចំកាត់ និងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៩៥ ចុះថ្ងៃទី ១៦ខែមិថុនា ឆ្នាំ១៩៩៩ របស់លោក ........... ជាមេធាវីអ្នកស្រី ឈចថ ស្ថិតក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងមកជំនុំជំរះបានតាមត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា លោក ជឹម ចន្ទ័សាស្ត្រា បានបើកគណនីលេខ ២១០០៥០១ នៅធនាគារសឹង្ហបូរី បានទាំងណែនាំ និងអនុញ្ញាតឲ្យឪពុករបស់លោកឈ្មោះ ជឹម សាំង និងប្អូនឈ្មោះ ជឹម ចន្ទ័ដារ៉ារិទ្ធ ជាអ្នកបើកប្រាក់ហើយពេលបើកប្រាក់ម្តងៗមិនដែលមានទំនាស់អ្វីទេ ។

យល់ឃើញថា ការដែលធនាគារសឹង្ហបូរីបើកប្រាក់ក្នុងគណនីលេខ ២១០០៥០១ ទៅឲ្យលោក ជឹម សាំង ជាឪពុកលោក ជឹម ចន្ទ័សាស្ត្រា គឺការបើកឲ្យនេះត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស របស់ធនាដូចនេះអ្នកស្រី ឈចថ មានសិទ្ធិប្តឹងទារប្រាក់ជាសម្បត្តិរួមពីលោក ជឹម សាំង វិញបាន ។

យល់ឃើញថា ការលើកឡើងរបស់អ្នកស្រី ឈចថ ក្នុងសារណាចុះថ្ងៃទី ២៤ ខែសីហា ឆ្នាំ១៩៩៩ សុទ្ធតែជារឿងនៃអង្គហេតុដែលសាលាឧទ្ធរណ៍បានពិចារណារួចហើយ ។

យល់ឃើញថា ការដែលមេធាវីដើមចោទលើឡើងថា ធនាគារសឹង្ហបូរីមានកំហុសក្នុងការបើកប្រាក់ឲ្យទៅលោក ជឹម សាំង ក្រោយមរណភាពរបស់លោក ជឹម ចន្ទ័សាស្ត្រា នោះជាការភ័ន្តច្រឡំពីព្រោះថា លិខិតចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ១៩៩៦ និងលិខិតចុះថ្ងៃទី ២៣ ខែមករា ឆ្នាំ១៩៩៧ របស់ ជឹម ចន្ទ័សាស្ត្រា បានអនុញ្ញាតឲ្យលោក ជឹម សាំងបើកប្រាក់ពីធនាគាររួចហើយ ដូច្នេះពេលវេលានៃការទៅបើកប្រាក់នោះជាសិទ្ធិរបស់លោក ជឹម សាំង ។

យល់ឃើញថា អ្នកស្រីតំណាងធនាគារសឹង្ហបូរី បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយប៉ុន្តែពុំបានមកចូលរួមសវនាការនោះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខអ្នកស្រី ប៉ុន្តែចាត់ជាចំពោះមុខ ។

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ២១៦ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ដែបានសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

វិនិច្ឆ័យសេចក្តីចំពោះមុខអ្នកស្រីឈចថ កំបាំងមុខតំណាងសាជីវកម្មធនាគារសឹង្ហបូរី

១-ទទួលបណ្តឹងសាទុក្ខលេខ ១៩៥ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៩៩ របស់លោក ........... ជាមេធាវីទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ប៉ុន្តែបដិសេធចោលដោយខុសនិងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ២១៦ ចុះថ្ងៃទី ០៦ ខែឧសភា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០៛ ដែលអ្នកស្រី ឈចថ បង់រួចហើយគឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជី កាន់ហឹបប្រាក់ ។

-ចំណាយក្នុងការប្រគល់ដីកាកោះចំនួន ១៥០០០៛ សរុប ១៩០០០៛ ។

-បង្គាប់ឲ្យអ្នកស្រី ឈចថ បង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៤-សាលដីការនេះប្រកាសនាសវនាកាជាសាធារណៈនៅថ្ងៃទី ០១ ខែសីហា ឆ្នាំ ២០០០ ។